Mekong Watch
3F AOKI Bldg., 1-12-11 Taito
Taito-ku, Tokyo 110-0016, Japan
Tel: +81-3-3832-5034, Fax: +81-3-3832-5039
E-mail: info@mekongwatch.org
Website: http://www.mekongwatch.org

# អត្ថបទសង្ខេបរបស់អង្គការ Mekong Watch ស្តីពីទំនប់ ប៉ាក មូន

**ទំនប់ ប៉ាក មូន** (Pak Mun Dam)៖
ប្រភេទទំនប់កាត់ទន្លេ កម្ពស់ ១៧ ម៉ែត្រ និងបណ្តោយ ៣០០ ម៉ែត្រ
សមត្ថភាពផលិតថាមពល ៖ ១៣៦ មេកាវ៉ាត់ (Megawatts)
ទីតាំង៖ ភូមិហ៊័រ ហ៊្យូវ (Hua Hew) ស្រុកខុនជាម (Khonjiam) ខេត្តអ៊ុប៊ុន រ៉ាឆាថានី (Ubon Rachathani)
(ស្ថិតនៅខ្សែទឹកទាគខាងលើ ក្បែរមាត់ច្រកចូលទន្លេមូន ចម្ងាយ ៥.៥ គីឡូម៉ែត្រពីចំនុចប្រសព្វរវាងទន្លេមូន និងទន្លេមេគង្គ)
ម្ចាស់គម្រោង៖ អាជ្ញាធរអគ្គីសនីនៃព្រះរាជាណាចក្រថៃ (EGAT)

## បញ្ហារបស់ទំនប់ ប៉ាក មូន (Pak Mun Dam)




ទំនប់ប៉ាកមូនអាចបង្រៀននូវមេរៀនជាច្រើនពីដំណើរការអភិវឌ្ឍន៍ទំនប់តាមដងទន្លេមេគង្គ ដល់សង្គមមនុស្សដែលនៅជុំវិញអាងទន្លេមេគង្គ។ គេនិយាយថា ទំនប់សង់កាត់ទន្លេមេគង្គមួយនេះ ផ្តល់ផលប៉ះពាល់ដល់បរិស្ថាន និងសង្គមតិចតួចតែប៉ុណ្ណោះ ប៉ុន្តែការពិត ផលប៉ះពាល់ពីទំនប់នេះ មានវិសាលភាពធំធេងនឹកស្មានមិនដល់ គឺវាបានបង្កឲ្យមានការធ្លាក់ចុះយ៉ាងគង្ហុកដល់បរិមាណត្រីនៅក្នុងអាងទន្លេ។ ការខូចខាតប្រព័ន្ធអេកូឡូស៊ី បាននាំឲ្យមានភាពក្រីក្រកាន់តែច្រើនឡើងៗ ក្នុងចំណោមអ្នកភូមិដែលរងផលប៉ះពាល់។ គម្រោងជាច្រើនដែលខកខានមិនបានរកដំណោះស្រាយជូនអ្នកភូមិរងផលប៉ះពាល់ ពាក់ព័ន្ធការចិញ្ចឹមជីវិត បានធ្វើឲ្យពួកគេមានការខឹងសម្បា និងប្រឆាំងជំទាស់នឹងគម្រោងអភិវឌ្ឍន៍ ដោយបង្កជាចលនាប្រឆាំងដ៏ធំ ដែលត្រូវគេកត់ត្រាទុកក្នុងប្រវត្តិសាស្ត្រនៃចលនាប្រជាជនថៃ។ វាក៏ជាបរាជ័យផ្នែកសេដ្ឋកិច្ចមួយផងដែរ នៅពេលថវិកាដែលគេគ្រោងសម្រាប់ទូទាត់ថ្លៃសំណង មិនគ្រប់គ្រាន់ ហើយដែលគ្មានខ្ទង់ថវិកាណាមួយសោះ ត្រូវគេបែងចែកសម្រាប់ផ្នែកជលផល។ មានចលនាមួយដ៏ធំបានកើតឡើងដើម្បីទាមទារថ្លៃសំណង ប៉ុន្តែការទាមទារនោះ នៅតែមិនអាចប៉ះប៉ូវការខាតបង់របស់ប្រជាជន ពាក់ព័ន្ធការចិញ្ចឹមជីវិតរបស់ពួកគេបាន

ទោះបីជាមានការបង្កើនថ្លៃដើមសាងសង់ទំនប់ដ៏ច្រើនសន្ធឹកសន្ធាប់ក៏ដោយ។

ទំនប់នេះ គឺជាគម្រោងមួយ ដែលមិនត្រឹមតែសម្រាប់ប្រទេសថៃប៉ុណ្ណោះទេ ប៉ុន្តែក៏មានការគាំទ្រពីធនាគារពិភពលោកផងដែរ ដូចនេះភាពបរាជ័យរបស់គម្រោងអភិវឌ្ឍន៍នេះ ត្រូវបានពិភពលោកទាំងមូលកត់ត្រាទុក។

ការស្ទង់មតិលើកដំបូងចំពោះទំនប់ប៉ាកមូន ធ្វើនៅឆ្នាំ១៩៦៧ដោយប្រទេសបារាំង គឺនៅខ្សែទឹកភាគខាងក្រោមចាប់ពីទីតាំងទំនប់បច្ចុប្បន្នចុះក្រោម។ ការសាងសង់ទំនប់នេះ ត្រូវបានពន្យាពេលនៅពេលនោះ ប៉ុន្តែបន្ទាប់ពីការស្ទង់មតិលើកក្រោយមកទៀតនៅទសវត្សឆ្នាំ១៩៨០ ក៏មានការសម្រេចមួយឲ្យកាត់បន្ថយកម្ពស់ទំនប់ពី១១៣ម៉ែត្រ មកត្រឹម១០៨ម៉ែត្រវិញ ធៀបជាមួយកម្រិតទឹកសមុទ្រ។ សំណើរសុំកាត់បន្ថយផលប៉ះពាល់ទៅលើប្រជាជនជាច្រើន ត្រូវបានទទួលយក ហើយនៅក្នុងខែឧសភា ឆ្នាំ១៩៩០ ក្នុងកិច្ចប្រជុំខុទ្ទកាល័យមួយ រដ្ឋាភិបាលថៃ បានអនុម័តយល់ព្រមឲ្យមានការសាងសង់ទំនប់នេះ។ ការងារសាងសង់បានចាប់ផ្ដើមក្នុងឆ្នាំ១៩៩១ និងសាងសង់រួចរាល់ក្នុងឆ្នាំ១៩៩៤។

## ទំនប់ប៉ាកមូន និងធនាគារពិភពលោក

ទំនប់ប៉ាកមូន ត្រូវបានសាងសង់ដោយមានជំនួយថវិកាដំបូងពីធនាគារពិភពលោ[1]។ ចាប់ពីពេលដែលទំនប់នេះត្រូវបានសាងសង់ ប្រជាពលរដ្ឋដែលធ្វើការលើវិស័យជលផល អ្នកសិក្សាអំពីត្រី និងអង្គការក្រៅរដ្ឋាភិបាលជាច្រើន បានប្រឆាំងចំពោះគម្រោងនេះ ដោយយកមូលហេតុថា ទំនប់នេះបានបង្កផលប៉ះពាល់ជាច្រើនដល់ពពួកត្រីផ្លាស់ទី ដែលរារាំងផ្លូវផ្លាស់ទីរបស់ពួកវាចុះឡើងពីទន្លេមេគង្គទៅកាន់ទន្លេមូន។ នៅពេលដែលក្រុមប្រឹក្សាភិបាលនៃធនាគារពិភពលោក ជួបប្រជុំសម្រេចផ្ដល់ថវិកាសាងសង់ក្នុងឆ្នាំ១៩៩១ អ្នកជំនាញដែលបានវាយតម្លៃពីផលប៉ះពាល់បរិស្ថានដោយផ្ទាល់ មកពីសហរដ្ឋអាមេរិក អាល្លឺម៉ង់ ព្រមទាំងអូស្ត្រាលី សុទ្ធតែបាន ប្រឆាំងជំទាស់ទាំងអស់ លើកលែងតែប្រទេសកាណាដា ដែលមានជំហរអនុប្បវាទ និងប្រទេសជប៉ុន ដែលតាមការរាយការណ៍ថាបានជុំរុញឲ្យអនុម័តការផ្ដល់ថវិកានេះ។ នៅក្នុងការវាយតម្លៃតាមដានគម្រោងនេះក្នុងឆ្នាំ១៩៩៨ ធនាគារពិភពលោក បានអះអាងថា **ការអនុវត្តន៍ការតាំងទីលំនៅថ្មី និងលទ្ធផលជាច្រើនទៀត បញ្ជាក់ពីបទពិសោធន៍ដ៏ល្អឥតខ្ចោះរបស់ខ្លួន ក្នុងចំណោមគម្រោងអភិវឌ្ឍន៍ទាំងអស់ដែលគាំទ្រដោយធនាគារ ជុំវិញដំណោះស្រាយការតាំងទីលំនៅថ្មី** [2] ។ ចំនុចនេះ បានធ្វើឲ្យមានការរិះគន់ពីពិភពលោកទាំងមូល។ ចាប់តាំងពីឆ្នាំ១៩៩៩ ប្រជាជនមូលដ្ឋាន បានរៀបចំជាចលនាដ៏ធំ ដោយធ្វើការទាមទាឲ្យមានការស្ដារឡើងវិញនូវបរិស្ថានធម្មជាតិ ជាជាងការទូទាត់សំណង



បំលាស់ទីរបស់ត្រីក្នុងទន្លេមេគង្គ(ប្រភព: MRC).

1 គម្រោងនេះ បានទទួលថវិកាចំនួន ៥៤ លានដុល្លារសហរដ្ឋអាមេរិក ជាគម្រោងថាមពលទីបី (៣) របស់ធនាគារអន្តរជាតិដើម្បីការស្ថាបនាឡើងវិញ និងការអភិវឌ្ឍន៍ (IBRD)។

2 បទពិសោធន៍ថ្មីៗជាជុំវិញការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តៈ ប្រទេសថៃ —ប៉ាកមូន។ នាយកដ្ឋានវាយតម្លៃប្រតិបត្តិការនៃធនាគារពិភពលោក ថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៩៨

ដែលបានទាញការគាំទ្រពីបរទេស។ ការចាប់អារម្មណ៍ ក៏កើតមានផងដែរចំពោះទំនប់នៅពេលមានការលើកឧទាហរណ៍ពីបរាជ័យគម្រោងអភិវឌ្ឍន៍របស់ធនាគារពិភពលោក ហើយចំនុចនេះក៏ត្រូវបានគេជ្រើសរើសជាករណីមួយ ដែលជុំរុញឲ្យមានការសើបអង្កេតឡើងវិញដោយគណកម្មការពិភពលោកស្តីពីទំនប់ (WCD) ចំពោះទំនប់ខ្នាតធំទាំងអស់នៅទូទាំងពិភពលោក។

**ទន្លេមូន និងធនធានត្រី**

ក្រោមឥទ្ធពលខ្យល់មូសុងត្រូពិច ប្រទេសថៃភាគឥសាន មានរដូវប្រាំង និងវស្សាខុសគេ។ ឈ្មោះ **មូន** មានន័យថា **បេតិកភ័ណ្ឌ**។ **ប៉ាកមូន** តំណាងឲ្យតំបន់នៅជុំវិញមាត់ច្រកចូលទន្លេមូន ហេតុដូច្នេះហើយទើបវាត្រូវបានជ្រើសរើសជាឈ្មោះទំនប់។ កម្រិតទឹករបស់ទន្លេដែលស្ថិតនៅខ្សែទឹកភាគខាងក្រោមនៃអាងទន្លេមេគង្គនឹងកើនឡើងនៅរដូវវស្សា ដោយ សារកំនើនកម្ពស់ទឹកភ្លៀង។ ត្រីជាច្រើន ត្រូវផ្លាស់ទីទៅភាគខាងលើ នៅពេលនោះ រួមទាំងទៅកាន់ទន្លេមូនផងដែរ។ នៅរដូវប្រាំវិញ នៅពេលភាពរាំងស្ងួតមានកម្រិតខ្ពស់ ត្រីត្រូវវិលត្រឡប់ទៅកាន់ទន្លេមេនៃអាងទន្លេមេគង្គវិញ ដោយសារទឹកនៅទីនោះនៅតែមានកម្រិតច្រើន។ (សូមមើលទូរលេខនៅខាងស្តាំ)

ខ្សែទឹកភាគខាងក្រោមនៃទន្លេមូន មានលក្ខណៈពិសេសត្រង់មានជួរទឹក និងអន្លង់ជាច្រើន ចំនែកឯខ្សែទឹកភាគកណ្តាលវិញ មានព្រៃលិចទឹកដ៏ច្រើនសន្ធឹកសន្ធាប់ ដែលជាទីជម្រកដ៏សមប្រកបសម្រាប់ត្រីពងកូន។ មានការបញ្ជាក់ថា មានត្រីចំនួន ២៧០ប្រភេទ បានរស់នៅទីនោះកាលពីមុន [3] ។ គេដឹងថាត្រីសម្បូរណាស់នៅខ្សែទឹកភាគខាងក្រោមនៃទន្លេមូន ហើយទោះបី ជាមិនមានផ្នែកណាមួយស្ថិតនៅជិតសមុទ្រ ប្រជាជននៅក្នុងភូមិចំនួនប្រមាណ៦០ សុទ្ធតែរស់នៅដោយពឹងផ្អែកលើរបរនេសាទ ជាជាងធ្វើកសិកម្ម។

**ផលប៉ះពាល់ពីការប៉ាន់ប្រមាណខុស**

ទន្លេមូន គឺជាតំបន់ពងកូនដ៏សំខាន់មួយក្នុងចំណាមតំបន់ពងកូនដ៏សំខាន់ជាច្រើន សម្រាប់ត្រីដែលផ្លាស់ទីឡើងមកពីទន្លេមេគង្គ។ ផលប៉ះពាល់ពីទំនប់ ប៉ាកមូន ទៅលើធនធានត្រីនៅខ្សែទឹកភាគខាងក្រោមនៃទន្លេមេគង្គ ត្រូវបានគេគិតថាមានវិសាលភាពធំធេង ប៉ុន្តែមិនមិនការស៊ើបអង្កេតណាមួយសោះចំពោះវាមុនពេលទំនប់ត្រូវបានសាងសង់។

ជាងនេះទៀត ថ្លៃទូទាត់សំណងដែលគេផ្តល់ជាថ្នូរចំពោះការសាងសង់ទំនប់ បានហើមរីកធំឡើងជិតបីដងធៀបជាមួយថ្លៃដែលប៉ាន់ស្មានដំបូង។

**ផែនការ ផ្ទុយពីការពិតនៃការទូទាត់សំណង និងផែនការកាត់បន្ថយហានិភ័យនៃទំនប់ប៉ាកមូន**

| | | ថ្លៃតាំងទីលំនៅថ្មី(ប្រាក់បាត) | ការផ្លាស់ទីលំនៅ | ដីកសិកម្មលិចទឹក | គម្រោងកាត់បន្ថយសម្រាប់ត្រី (ប្រាក់បាត) |
|---|---|---|---|---|---|
| ដែលបានគ្រោង | | ៣៩៤.៧៧ លាន(១៩៨៨) | ២៤៨ គ្រួសារ (១៩៨៥) | -- | -- |
| ដែលជាការពិត | | ១,១១៣.១ លាន (១៩៩៩) | ៩៤៣ គ្រួសារ (១៩៩៤) | ៧០៦ គ្រួសារ (១៩៩៤) | ៣០៥.៥៥ លាន (១៩៩៥-១៩៩៨) |

(ប្រភព៖ ទំនប់ប៉ាកមូន អាងទន្លេមេគង្គ ប្រទេសថៃ៖ ករណីសិក្សារបស់គណកម្មការពិភពលោកស្តីពីទំនប់ (WCD) ឆ្នាំ២០០០)

[3] យោងតាមការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រដោយគណកម្មការទន្លេមេគង្គ (MRC)

អ្នកភូមិជាច្រើន ប្រឆាំងជំទាស់យ៉ាងដាច់អហង្ការចំពោះការសាងសង់ទំនប់ បន្ទាប់ពីការសាងសង់កំពុងដំណើរការ។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលថៃ មិនបានពិនិត្យមើលឡើងវិញឡើយចំពោះគម្រោងនេះ ដូចនេះអ្នកភូមិក៏បានផ្លាស់ប្តូរជំហរ ដោយទាមទារថ្លៃសំណងវិញ ហើយបានបន្តការតវ៉ារហូតមក។ ក្នុងឆ្នាំ១៩៩៥ រាជរដ្ឋាភិបាលថៃ បានអនុម័តផ្តល់ប្រាក់ ចំនួន ៣០,០០០ បាត ក្នុងមួយឆ្នាំដល់គ្រួសារនីមួយៗ សម្រាប់រយៈពេលបីឆ្នាំនៃការសាងសង់ទំនប់ ដែលជាសំណងចំពោះធនធានជលផល។ ការផ្តល់នេះបានបន្តរហូតដល់ឆ្នាំ១៩៩៩ ជាឆ្នាំចុងក្រោយ ដែលពេលនោះ ការផ្តល់ត្រូវបានបង្កើនដល់ ៩០,០០០ បាត (សាច់ប្រាក់ ៣០,០០០ បាត និង ៦០,០០០ បាត ជាប្រាក់តម្កល់គាំទ្រសហករកសិកម្ម)។ ចំនួនគ្រួសារដែលទទួលបានសំណង មានចំនួន ៣,៩៦៦ គ្រួសារ ដែលចំនួននេះធ្វើឲ្យការផ្តល់ប្រាក់កើនឡើងដល់ ៣៩៥.៦ លានបាត។

ជណ្តើរត្រី ដែលសាងសង់ និងកម្មវិធីស្តារឡើងវិញនូវធនធានមច្ឆជាតិ ដែលបានចាប់ផ្តើមបន្ទាប់ពីទំនប់សាងសង់រួច មិនមានប្រសិទ្ធភាពឡើយ ផ្ទុយមកវិញ ធនធានជលផលក្នុងតំបន់ត្រូវបានបំផ្លាញ។ អ្នកភូមិជាច្រើន បានរស់នៅក្នុងស្ថានភាពជាកម្មករចំណាកស្រុកបណ្តោះអាសន្ននៅតាមទីក្រុង ប៉ុន្តែវិបត្តិសាច់ប្រាក់ក្នុងឆ្នាំ១៩៩៧ បានធ្វើឲ្យអ្នកភូមិជាច្រើនបាត់បង់ការងារ និងត្រូវវិលត្រឡប់ទៅកាន់ភូមិកំណើតរបស់ពួកគេវិញ។ ការទាមទារឲ្យបង្កើនថ្លៃសំណង បានកើនឡើងឥតឈប់ឈរក្នុងចំណោមអ្នកភូមិដែលមិនអាចរករបរចិញ្ចឹមជីវិតតាមរយៈការនេសាទ។ កិច្ចប្រជុំខុទ្ទកាល័យនៃអាណត្តិទីពីររបស់រដ្ឋបាលលោក ឈួន (Chuan Leekpai) ក្នុងឆ្នាំ១៩៩៨ បានសម្រេចមិនផ្តល់សំណងជាថ្មីដល់អ្នកភូមិដែលធ្លាប់បានទទួលសំណងម្តងហើយ ចំពោះគម្រោងសាងសង់ទំនប់។

អ្នកភូមិជាច្រើន បានអស់ទំនុកចិត្តទៅលើរដ្ឋាភិបាល ប៉ុន្តែបានវិនិច្ឆ័យថា វាពិតជាលំបាកណាស់ក្នុងការស្តារឡើងវិញនូវជីវភាពរស់នៅរបស់ពួកគេជាមួយថ្លៃសំណងដែលបានទទួល ដូចនេះពួកគេបានធ្វើការអំពាវនាវសារជាថ្មីសុំឲ្យរុះរើទំនប់ចេញ។ នៅក្នុងខែមីនា ឆ្នាំ១៩៩៩ អ្នកភូមិមួយក្រុមធំមានគ្នារាប់ពាន់នាក់ រួមទាំងអ្នកភូមិរងផលប៉ះពាល់ពីទំនប់ផ្សេងៗផង បាននាំគ្នាមកកាន់កាប់ទីតាំងទំនប់ប៉ាកមូន ដោយបង្កើតភូមិឈ្មោះ *Mae Mun Man Youn* (ទន្លេមូនជាអមតៈ) ជាវេទិការសម្រាប់ជជែកពិភាក្សា។ សកម្មភាពនេះ បានទាក់ទាញចំណាប់អារម្មណ៍ពីគ្រប់មជ្ឈដ្ឋាននៅទូទាំងប្រទេស។ លើសពីនេះទៀត ការបញ្ឈប់ ការសង់ទំនប់ដ៏ធំថ្មីមួយនៅសហរដ្ឋអាមេរិក បានធ្វើឲ្យការប្រឆាំងជំទាស់នឹងទំនប់ខ្នាតធំបានរីករាលដាលទូទាំងសកលលោក ហើយក៏បានទាញចំណាប់អារម្មណ៍ដល់ទំនប់ប៉ាកមូន ដែលជាឧទាហរណ៍ពីភាពបរាជ័យនៃគម្រោងដែលគាំទ្រថវិកាដោយ ធនាគារពិភពលោក។ ដូចនេះ ការអំពាវនាវរបស់អ្នកភូមិឲ្យរុះរើទំនប់ចេញ ទទួលបានការដឹងឮពាសពេញពិភពលោក។ នៅពេលនោះ ចំនួនគ្រួសារដែលអះអាងថាខ្លួនរងផលប៉ះពាល់ពីទំនប់ប៉ាកមូន បានកើនដល់ប្រមាណ ៦,០០០ គ្រួសារ។

## ការសាកល្បងបើកទ្វារទឹក និងការវាយតម្លៃឡើងវិញ

ក្នុងឆ្នាំ២០០១ គណបក្សថៃរ៉ាក់ថៃ (ថៃស្រលាញ់ថៃ) ដែលគាំទ្រលោក ថាក់ស៊ីន ស៊ីណាវ៉ាត្រា (Thaksin Shinawatra) ដែលបានប្រកាសពីក្តីកង្វល់ចំពោះជនក្រីក្រ បានឈ្នះឆ្នោតលើសលប់។ នាយករដ្ឋមន្រ្តី ថាក់ស៊ីន បានអនុម័តយល់ព្រមឲ្យបើកទ្វារទំនប់ទឹករយៈពេលខ្លី ដើម្បីស្ទង់មតិ [4] និងបានបញ្ជាឲ្យសាកលវិទ្យាល័យអ៊ុប៊ុន រ៉ាឆាថានី ធ្វើការស៊ើបអង្កេត និងចងក្រងទុកជាឯកសារនូវរាល់ផលប៉ះពាល់ទាំងអស់។ បន្ទាប់ពីទ្វារទំនប់ទឹកបានបើក បរិស្ថានទន្លេមានភាពប្រសើរឡើងខ្លាំង ហើយផលចាប់ក៏មានការកើនឡើងផងដែរ។ អ្នកភូមិ និងអង្គការក្រៅរដ្ឋាភិបាល បានធ្វើការរួមគ្នាអំពីការស្ទង់មតិមួយឈ្មោះថា **ថៃប្ញាន** (ភូមិថៃ) ហើយបានបង្ហាញលទ្ធផលរបស់វាដោយផ្អែកលើចំណេះដឹងអ្នកភូមិសុទ្ធសាធ។ សកម្មភាពបែបនេះ បានទទួលការ

[4] ដំបូងឡើង ការបើកទ្វារទំនប់ទឹក ធ្វើឡើងសម្រាប់រយៈពេលពីរ ឬបីខែបីខែប៉ុណ្ណោះ ប៉ុន្តែដើម្បីសម្របតាមក្តីបំណងរបស់ភាគីទាំងពីរ ទាំងប្រជាពលរដ្ឋ និងសាកលវិទ្យាល័យអ៊ុប៊ុន រ៉ាឆាថានី ទ្វារទំនប់ទឹកបន្តបើកចាប់ពីខែមិថុនា ឆ្នាំ២០០១ ដល់ខែវិច្ឆិការ ឆ្នាំ២០០២

គាំទ្រយ៉ាងពេញទំហឹងពីក្រុមអ្នកស្រាវជ្រាវជាន់ខ្ពស់ជាច្រើន។



ក្រុមស្រាវជ្រាវរបស់សាកលវិទ្យាល័យ បានស្នើឲ្យរក្សាទ្វារទឹកនោះចំហរពេញមួយឆ្នាំ ដើម្បីជាមូលដ្ឋានសាកល្បងសម្រាប់ប្រាំឆ្នាំ ដោយលើកយកមកអះអាងនូវទូរលេខជាច្រើនទាក់ទងកម្រិតជីវភាពក្រីក្ររបស់អ្នកភូមិ និងភាពមិនសមរម្យក្នុងការទទួលបានផ្នែកសេដ្ឋកិច្ចពីការផលិតថាមពលអគ្គីសនី ដោយមានបង្ហាញជាឯកសារយោងស្តីពីការរើបឡើងវិញនូវធនធានជលផលតាមរយៈការបើកទ្វារទឹក និងដោយបានកត់សំគាល់ថា ការបើកទ្វារទឹក នឹងមិនមានផលប៉ះពាល់ដល់ការផ្គត់ផ្គង់ថាម ពលអគ្គីសនីឡើយ ផ្ទុយមកវិញវានឹងជួយធ្វើឲ្យប្រសើឡើងផ្នែកសេដ្ឋកិច្ចដល់ប្រជាជនក្រីក្រនៅក្នុងភូមិទៅវិញ។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលថៃ មិនបានព្រមព្រៀងតាមសំណើសុំនេះទេ ប៉ុន្តែបានសម្រេចបើកទ្វារទឹកសម្រាប់រយៈពេល៤ខែតែប៉ុណ្ណោះក្នុងមួយឆ្នាំ (ពីខែកក្កដាដល់ខែតុលា)[5]។

ខណៈពេលដែលខ្លួនកំពុងអះអាងពីការលុបបំបាត់នូវរាល់ផលប៉ះពាល់ទាំងអស់ទៅលើធនធានជលផល ពួកគេបែជាបើកទ្វារទឹកមិនចំពេលបំលាស់ទីរបស់ត្រីទៅវិញ[6]។

**ការបើកទ្វារទឹករយៈពេល៤ខែប្រចាំឆ្នាំ**

ការបើកទ្វារទឹករយៈពេល៤ខែលើកដំបូងក្នុងឆ្នាំ២០០៣ មិនបានធ្វើឲ្យប្រសើរឡើងដល់ធនធានជលផលទេ ដូចនេះនៅឆ្នាំបន្ទាប់ ក្នុងឆ្នាំ២០០៤ អ្នកភូមិបានស្នើរឲ្យរដ្ឋាភិបាលផ្លាស់ប្តូរពេលវេលានៃការបើកទ្វារទឹក ដើម្បីឲ្យស៊ីជាមួយពេលវេលានៃការផ្លាស់ទីរបស់ត្រី។ ឧតកាល័យ បានអនុម័តយល់ព្រមផែនការមួយ ដោយអនុញ្ញាតឲ្យបើកទ្វារទឹកពីថ្ងៃទី១ ខែឧសភា ដល់ថ្ងៃទី៣១ ខែសីហា ហើយឆ្នាំនោះទ្វារទឹកបានបើកនៅខែមិថុនា។

ទោះបីជាយ៉ាងនេះក្តី ក្នុងឆ្នាំ២០០៧ ការបើកទ្វារទឹកត្រូវបានបញ្ឈប់។ បន្ទាប់ពីភាពជ្រួលច្របល់នយោបាយ ដែលផ្តើមចេញពីការដួលរលំរបស់នាយករដ្ឋមន្ត្រីថាក់ស៊ីន និងការចូលមកគ្រប់គ្រងអំណាចដោយនាយករដ្ឋមន្ត្រី ស៊ូរ៉ាយុទ្ធ ក្នុងរដ្ឋប្រហារ ឧទ្ទកាល័យថ្មី បានសម្រេចចិត្តមិនបន្តបើកទ្វារទំនប់ទៀត ដោយនិយាយថា មានហត្ថលេខាក្នុងញត្តិចំនួន២០,០០០ ដាក់មកកាន់រដ្ឋាភិបាលខ្លួនឲ្យបញ្ឈប់ការបើកទ្វារទឹកបន្តទៀត។ កិច្ចចចាររវាងអ្នកភូមិ និងអ្នកស្រាវជ្រាវ និងតំណាងរដ្ឋាភិបាលដែលគាំទ្រការបិទ បានបន្តឥតដាច់ស្រាច់ជាមួយគណកម្មាធិការដើម្បីគាំទ្រការប្រតិបត្តិអាងទឹកប៉ាកមូន ដែលបង្កើតឡើងក្នុងឆ្នាំ២០០៨ ក្នុងខេត្តអ៊ុប៊ុន រ៉ាឆាថានី ដែលក្រោយមកក៏បានសម្រេចឲ្យបើកទ្វារទឹកសម្រាប់រយៈពេល៤ខែ។ លក្ខណៈវិនិច្ឆ័យថ្មីមួយ ត្រូវបានបង្កើតឡើង ជាការឆ្លើយតបនឹងបញ្ហា គឺនៅពេលដែលបរិមាណទឹកហូរឆ្លងកាត់ចំនុចវាស់ស្ទង់មួយ ដែលហួសពីកម្រិតកំណត់ នៅពេលនោះទ្វារទឹកនឹងត្រូវបើក។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារបម្រែបម្រួលផ្នែករដ្ឋបាលឥតឈប់ឈរ សេចក្តីសម្រេចនេះ ប្រែជាឥតប្រយោជន៍។

---

[5] យោងតាមអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក រយះពេលបើកទ្វារទឹក៤ខែ ត្រូវបានកំណត់ធ្វើនៅក្នុងរដូវវស្សា គឺនៅពេលដែលកម្រិតទឹកទន្លេមេគង្គខាងក្រោមទំនប់ កើនឡើងខ្ពស់ល្មម ដល់កម្រិតមួយដែលមើលមិនឃើញពីភាពខុសគ្នានៃកម្ពស់ទឹករវាងទឹកខាងលើ និងទឹកខាងក្រោមទំនប់ ហើយដែលជាពេលគេស្ទើរតែមិនអាចផលិតថាមពលអគ្គីសនីបាន។

[6] យោងតាមចំណេះដឹងរបស់ប្រជាជន រដូវបំលាស់ទីរបស់ត្រីដែលឡើងឆ្ពោះទៅមាត់ច្រកចូលទន្លេមូន កើតមានឡើងចាប់ពីបំណាច់ខែឧសភា រហូតដល់ខែកក្កដា ហើយធ្វើបំលាស់ទីចុះមកវិញនៅអំឡុងខែវិច្ឆិកា

ជាថ្មីម្តងទៀត នៅក្នុងឆ្នាំ២០១១ ការបញ្ចុះបញ្ចូលរបស់អ្នកភូមិបានបណ្តាលឲ្យមានការបង្កើតឡើងនូវគណកម្មាធិការនៃអ្នកជំនាញការនានា និងសំណើរសុំផ្សេងៗដែលធ្វើឡើងដើម្បីបើកទ្វារទឹក ប៉ុន្តែរាជរដ្ឋាភិបាលថៃ មិនបានទទួលយកពួកវាទេ។

**អនុសាសន៍៖**

ខណៈពេលដែលការអភិវឌ្ឍន៍តាមដងទន្លេមេគង្គ បានបង្កផលប៉ះពាល់អវិជ្ជមានដល់ត្រីនៅក្នុងអាងទឹកទន្លេភាគខាងក្រោម ការស្តារឡើងវិញនូវបរិស្ថានធម្មជាតិក្នុងទន្លេមូន នឹងជះឥទ្ធពលយ៉ាងខ្លាំងដល់ការងារថែរក្សាប្រព័ន្ធអេកូឡូស៊ីក្នុង អាងទន្លេមេគង្គទាំងមូល។ រាជរដ្ឋាភិបាលថៃ គួរតែទទួលយកអនុសាសន៍មួយចំនួន ដែលផ្តល់ដោយសាកលវិទ្យាល័យអ៊ុប៊ុន រ៉ាឆាថានី ក្នុងឆ្នាំ២០០២ ដែលស្នើរឲ្យមានការបើកទ្វារទឹកឲ្យបានពេញលេញសម្រាប់រយៈពេលប្រាំឆ្នាំ។